CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៦ ខែកក្កដាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ស្ថិតិសុវត្ថិភាពសាធារណៈសម្រាប់ចុងសប្តាហ៍នៃទិវាឯករាជ្យជាតិ

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចបានលើកទឹកចិត្តឱ្យប្រជាជនទាំងអស់រីករាយនឹងថ្ងៃឈប់សម្រាកនៅថ្ងៃទី ៤ ខែកក្កដាដោយសុវត្ថិភាពនៅផ្ទះនិងបានរំឭកពលរដ្ឋថារាល់កាំជ្រួចរួមទាំងកាំជ្រួចដែលមានស្លាកបញ្ជាក់ថាមានសុវត្ថិភាពនិងសមរម្យគឺសុទ្ធតែខុសច្បាប់ទាំងអស់នៅឡុងប៊ិច។

នៅមុនថ្ងៃបុណ្យឯករាជ្យជាតិទីក្រុងបានផ្សព្វផ្សាយសារអំពីរបៀបអបអរសាទរដោយសុវត្ថិភាពដើម្បីអប់រំសាធារណជនអំពីគ្រោះថ្នាក់ដែលអាចកើតឡើងមកពីការដុតកាំជ្រួចក៏ដូចជាផលអាក្រក់នៃការដុតកាំជ្រួចដោយខុសច្បាប់ផងដែរ។ នៅឆ្នាំនេះទីក្រុងឡុងប៊ិចនិងតំបន់នានាបានមានសកម្មភាពដុតកាំជ្រួចខុសច្បាប់ជាច្រើន។

តាមរយៈមជ្ឈមណ្ឌលព័ត៌មានកាំជ្រួចរបស់ទីក្រុងជម្រើសនៃការរាយការណ៍សកម្មភាពបាញ់កាំជ្រួចខុសច្បាប់ជាច្រើនត្រូវបានផ្តល់ដល់សហគមន៍តាមរយៈគេហទំព័រ www.longbeach.gov/fireworks។ ជម្រើសនៃការរាយការណ៍រួមមានការផ្ញើអ៊ីមែលទៅផ្នែកល្បាតប៉ូលីសក្នុងមូលដ្ឋានដោយទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងទីក្រុងឬដាក់ពាក្យបណ្តឹងតាមរយៈផតថលសាធារណៈរបស់ព្រះរាជអាជ្ញាក្រុងសម្រាប់ពាក្យបណ្តឹងទាក់ទងនឹងកាំជ្រួចដែលអាចផ្ទុករូបថតនិងវីដេអូបាន។ ចាប់តាំងពីការបើកដំណើរការនូវផតថលនៅថ្ងៃទី ២២ ខែមិថុនាមកបណ្តឹងជាង 460 ដែលទាក់ទងនឹងកាំជ្រួចត្រូវបានរាយការណ៍ទៅព្រះរាជអាជ្ញាក្រុង។ ការិយាល័យព្រះរាជអាជ្ញាបានផ្ញើលិខិតចំនួន 205 សំបុត្រទៅអាស័យ

ដ្ឋានដែលពាក្យបណ្ដឹងកាំជ្រួចត្រូវបានរកឃើញ។ លិខិតនោះបានជូនដំណឹងដល់អ្នកទទួលថាការដុតកាំជ្រួចខុសច្បាប់គឺជាការរំខានដល់សាធារណៈហើយការកាត់ទោសយោងទៅតាមក្រមព្រហ្មទណ្ឌមាត្រា 373a (គឺត្រូវជាប់ពន្ធនាគាររហូតដល់ 1 ឆ្នាំនិងពិន័យជាប្រាក់ $1,000 ដុល្លារ) អាចនឹងចាប់ផ្តើមប្រសិនបើភាពរំខានជាសាធារណៈនេះនៅតែបន្តកើតមាន។

ឆ្នាំនេះកាំជ្រួចចំនួន 808 ផោនត្រូវបានរកឃើញដោយក្រុមអ្នកស៊ើបអង្កេតនៃមន្ទីរពន្លត់អគ្គីភ័យនៃទីក្រុងឡុងប៊ិច (LBFD) និងមន្ទីរប៉ូលីសនៃទីក្រុងឡុងប៊ិច (LBPD) ក្នុងរដូវដែលសកម្មភាពដុតកាំជ្រួចឈានដល់កំរិតខ្ពស់បំផុត (គឺរវាងថ្ងៃទី 22 ខែឧសភាដែលជាថ្ងៃដំបូងនៃចុងសប្តាហ៍នៃទិវារំឭកថ្ងៃចងចាំដល់ខែកក្កដាថ្ងៃទី 4 ឆ្នាំ ២០២០)។ កាំជ្រួចទាំងនេះត្រូវបានរឹបអូសដោយក្រុមស៊ើបអង្កេតនៃមន្ទីរពន្លត់អគ្គីភ័យទីក្រុងឡុងប៊ិចនិងក្រុមការងារពិសេសសម្រាប់ការបស់ចោលដោយសុវត្ថិភាពនៃការិយាល័យគ្រឿងស្រវឹងថ្នាំជក់និងអាវុធ (ATF) តាមរយៈការិយាល័យសេនាប្រមុខអគ្គិភ័យនៃរដ្ឋកាលីហ្វ័រញ៉ា។ ដោយឡែកមន្ទីរប៉ូលីសនៃទីក្រុងឡុងប៊ិចបានចេញលិខិតពិនយ័ចំនួន 59 ដល់បុគ្គលម្នាក់ៗសម្រាប់សកម្មភាពដែលទាក់ទងនឹងការដុតកាំជ្រួចក្នុងរយៈពេលប៉ុន្មានសប្តាហ៍ដែលឈានមកដល់ថ្ងៃបុណ្យឯករាជ្យជាតិនេះ។ នៅថ្ងៃទី 4 ខែកក្កដាការអនុវត្តន៍ច្បាប់របស់ប៉ូលីសក្នុងក្រុងបានបណ្ដាលឲ្យមានការចាប់ខ្លួនឧក្រិដ្ឋជនចំនួន 13 អ្នកករណីការចាប់ខ្លួនមជ្ឈឹមចំនួន 10 និងការចេញលិខិតពិនយ័ទាក់ទងនឹងការដុតកាំជ្រួចចំនួន 13 បន្ថែមទៀត។

ក្នុងរយៈពេល 24 ម៉ោងនៃថ្ងៃទី 4 ខែកក្កដាមានការដាក់ពាក្យបណ្ដឹងតាមទូរស័ព្ទដែលទាក់ទងទៅនឹងកាំជ្រួចចំនួន 779 ទៅកាន់ការិយាល័យបញ្ជូនរបស់ទីក្រុង។ ក្នុងរយៈពេល 24 ម៉ោងនៃថ្ងៃទី 4 ខែកក្កដាការិយាល័យបញ្ជូនបានមើលឃើញការកើនឡើងនៃការទូរស័ព្ទចូលចំនួន 67% បើប្រៀបធៀបទៅនឹងថ្ងៃធម្មតា។ បុគ្គលិកការិយាល័យបញ្ជូនបានទទួលការទូរស័ព្ទចូលចំនួន 3,854 (ទាំង 9-1-1 និងខ្សែមិនអាសន្ន) ដែលក្នុងនោះ 1,301 មានការអំពាវនាវរកសេវាកម្មជំនួយ។ នៅក្នុងការប្រៀបធៀបនៅថ្ងៃធម្មតាការិយាល័យបញ្ជូនទទួលការទូរស័ព្ទចូលចំនួនប្រមាណ 2,301 (ទាំង 9-1-1 និងខ្សែមិនអាសន្ន) និងប្រហែល 566 ជាការអំពាវនាវរកសេវាកម្មជំនួយ។ ក្នុងអំឡុងពេលនៃចំនួនអតិបរមានៃការហៅចូលដែលនៅចន្លោះម៉ោង 8:30 យប់ដល់ 9:15 យប់ការិយាល័យបញ្ជូន បានទទួលការហៅចូលចំនួន 449 (ទាំង 9-1-1 និងខ្សែមិនអាសន្ន) នោះមានន័យថាជាមធ្យមគឺមានការហៅចូល 10 ដងក្នុងមួយនាទី។ បុគ្គលិកនៅក្នុងការិយាល័យបញ្ជូនបានបង្កើនដល់ទៅ 40 ភាគរយនៅចន្លោះម៉ោង 7 យប់និងម៉ោង 11 យប់ដើម្បីត្រៀមសម្រាប់ការកើនឡើងនៃចំនួនការហៅចូល។

កាំជ្រួចតូចៗរួមទាំងផ្កាភ្លើងបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិរាប់ពាន់លានដុល្លារជារៀងរាល់ឆ្នាំហើយបណ្តាលឱ្យមានអ្នករងរបួសជាច្រើនដែលភាគច្រើនអ្នករងគ្រោះនោះគឺកុមារ។ ឆ្នាំនេះមន្ទីរពន្លត់អគ្គីភ័យនៃទីក្រុងឡុងប៊ិចបានឆ្លើយតបទៅនឹងការទូរស័ព្ទបណ្តឹងទាក់ទងនឹងកាំជ្រួចចំនួន 23 ដូចជាករណីភ្លើងឆេះដើមឈើ / ភ្លើងឆេះព្រៃ / ភ្លើងឆេះស្មៅ/ភ្លើងឆេះសំរាមនិងភ្លើងឆេះផ្ទះឬផ្ទះល្វែងដែលបណ្តាលមកពីការបាញ់កាំជ្រួច។

ស្របនឹងខោនធី Los Angeles ឆ្នេរសមុទ្រទាំងអស់នៅឡុងប៊ិចបានបិទជាសាធារណៈនៅចុងសប្តាហ៍នៃទិវាឯករាជ្យជាតិ។ ព្រឹត្តិការណ៍ដូចជាការបង្ហាញកាំជ្រួចពិធីជប់លៀងតាមសង្កាត់និងការជួបជុំធំៗដទៃទៀតក៏ត្រូវបានហាមឃាត់ផងដែរ។

លើសពីនេះទៀតរដ្ឋបានតម្រូវឱ្យបិទបារ៍កន្លែងទទួលទានអាហារក្នុងហាងនិងកន្លែងខាងក្នុងនៅតាមសារមន្ទីរនៅទូទាំងខោនធី Los Angeles ក្នុងកិច្ចប្រឹងប្រែងដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19។ ដើម្បីធានានូវការអនុលោមតាមការបិទជាកាតព្វកិច្ចនិងពិធីសារសុវត្ថិភាពទីក្រុងបានបង្កើតក្រុមការងារពិសេសដែលផ្តោតលើទីតាំងដើម្បីផ្សព្វផ្សាយការអប់រំដល់អាជីវកម្មនិងត្រួតពិនិត្យអាជីវកម្មផ្សេងៗដើម្បីផ្ទៀងផ្ទាត់ការអនុលោមតាមបទបញ្ជាសុខភាពរបស់ទីក្រុង។

ចាប់ពីថ្ងៃទី 2 ខែកក្កដាដល់ថ្ងៃទី 4 ខែកក្កដាក្រុមការងារបានចុះទៅទីតាំងចំនួន 655 ដែលភាគច្រើនជាបារ៍និងភោជនីយដ្ឋានហើយបានចេញលិខិតពិន័យរដ្ឋបាលចំនួន 9 ដល់អាជីវកម្មដែលបានរំលោភបទបញ្ជា។ គឺចាំបាច់ណាស់ដែលរាល់អាជីវកម្មបន្តអនុវត្តតាមបទបញ្ជាសុខភាពនិងពិធីសារទាំងអស់ដើម្បីធានាសុវត្ថិភាពដល់មនុស្សគ្រប់គ្នា។ ដើម្បីរាយការណ៍អំពីការរំលោភបំពានប្រជាពលរដ្ឋអាចទូរស័ព្ទមកលេខ 562.570.2633 ឬចូលទៅកាន់គេហទំព័រ www.longbeach.gov/lbds។

ប្រជាជនអាចបន្តរាយការណ៍អំពីសកម្មភាពនៃការដុតកាំជ្រួចខុសច្បាប់ដោយមានជម្រើសក្នុងការបញ្ចូលភស្តុតាងនៅលើគេហទំព័រ www.longbeach.gov/fireworks។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័សង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #